# សំណួរដែលគេឧស្សាហ៍សួរ អំពីសាលាឆាទ័រ/CHARTER SCHOOL FAQs

## ១. តើសាលាឆាទ័រជាអ្វី?

សាលាឆាទ័រគឺជាសាលារដ្ឋដែលមានរដ្ឋបាលគ្រប់គ្រងដោយឯករាជ្យ។ សាលាទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្ដល់ឱកាសកាន់តែច្រើនដល់ក្មេង ឲ្យទទួលជោគជ័យក្នុងការសិក្សា។ ឆាទ័រគឺជាអង្គការតតរកកម្រៃ និង មិនប្រកាន់បក្សពួក ដែលអនុញ្ញាតឲ្យដោយ ក្រុមប្រឹក្សាភិបាលអប់រំក្នុងតំបន់ (The chartering school district)។ សាលាឆាទ័រនីមួយៗមាន ក្រុមប្រឹក្សាភិបាល និង បុគ្គលិក រៀងៗខ្លួន ហើយជាស្ថាប័នអប់រំដែលធ្វើឡើង ដោយឡែក ឯករាជ្យពីក្រសួងអប់រំក្នុងតំបន់។ ច្បាប់សាលាឆាទ័រនៃរដ្ឋផិនស៊ីលវេនញ៉ា Act 22 នៃឆ្នាំ១៩៩៧ មិនតម្រូវឲ្យសាលាឆាទ័រធ្វើតាមតម្រូវការ របស់តំបន់ និង របស់រដ្ឋ ដូចតាមទម្លាប់នៃសាលារដ្ឋនោះទេ។ សាលាឆាទ័រមិនបាច់ធ្វើតាមបទបញ្ជានៃការអប់រំជាច្រើន លើកលែងតែករណីដែលទាក់ទងនឹង ការមិនរើសអើង សុខភាព និង សុវត្ថិភាព និង ការទទួលខុសត្រូវ។

សាលាឆាទ័រជួលគ្រូបង្រៀនដោយខ្លួនឯង រៀបចំកម្មវិធីសិក្សា ជ្រើសរើសសៀវភៅមេរៀន និង សម្ភារៈបង្ហាត់បង្រៀនផ្សេងទៀត សម្រេចរយៈពេលរៀនប្រចាំថ្ងៃ និង រយៈពេលនៃឆ្នាំសិក្សា សម្រេចពី ចំនួន និង ប្រភេទ នៃសកម្មភាពក្រៅម៉ោងសិក្សា និង អ្វីៗជាច្រើនទៀត។

## ២. តើខ្ញុំចុះឈ្មោះកូនរបស់ខ្ញុំឲ្យចូលរៀននៅសាលាឆាទ័រដោយវិធីណា?

ដោយសារសាលាឆាទ័រដំណើរការដោយឯករាជ្យពី ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា និង ដោយឡែកៗពីគ្នា ដោយមានករណីលើកលែងតែពីរបីតែប៉ុណ្ណោះ លោកអ្នកត្រូវតែទាក់ទងទៅសាលាឆាទ័រដោយផ្ទាល់។ បញ្ជីឈ្មោះសាលាឆាទ័រមាននៅត្រង់នេះ។

## ៣. តើខ្ញុំអាចប្តូរកូនខ្ញុំពីសាលាឆាទ័រមួយទៅសាលាឆាទ័រមួយទៀតដោយវិធីណា?

លោកអ្នកមិនអាចប្តូរបានទេ។ សាលាឆាទ័រនីមួយៗគឺជា ស្ថាប័នអប់រំក្នុងតំបន់ (LEA) ដោយឡែកៗពីគ្នា។ សាលាឆាទ័រនីមួយៗឯករាជ្យពី ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ហើយក៏ដាច់ពីសាលាឆាទ័រផ្សេងៗទៀតដែរ លើកលែងតែសាលាឆាទ័រណាដែលមានការគ្រប់គ្រងដោយសាលាឆាទ័រតែមួយ។ គ្មាន «ប្រព័ន្ធ» សាលាឆាទ័រទេ នៅទីក្រុងហ្វីឡាដែលហ្វ្យា នេះ។

មាតាបិតាត្រូវដាក់ពាក្យស្នើសុំទៅសាលាឆាទ័រនីមួយៗ ដែលពួកគាត់ចាប់អារម្មណ៍។ លោកអ្នកអាចមើលបញ្ជីឈ្មោះសាលាឆាទ័រ ដើម្បីរកព័ត៌មានសម្រាប់ទាក់ទងទៅសាលា។ ការិយាល័យនៃសាលាឆាទ័រមិនមែនជាកន្លែងទទួលសិស្សឲ្យចូលរៀននៅសាលាឆាទ័រ នោះទេ។

## ៤. តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះសកម្មភាពរបស់សាលាឆាទ័រ និង បុគ្គលិករបស់សាលាឆាទ័រ សាលាឆាទ័រ ឬ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា?

ជាសាលាឯករាជ្យ ទទួលប្រាក់ជំនួយពីរដ្ឋ សាលាឆាទ័រនីមួយៗមាន ក្រុមប្រឹក្សាភិបាល រៀងៗខ្លួន។ យោងទៅលើច្បាប់សាលាឆាទ័រ (Act 22 នៃឆ្នាំ១៩៩៧) សាលានេះជាអង្គការមិនយកកម្រៃ មិនប្រកាន់បក្សពួក ហើយ «មានការទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត គ្រប់ប្រភេទទាំងអស់ ដែលបណ្តាលមកពីការប្តឹងផ្តល់ដែលទាក់ទងនឹងប្រតិបត្តិការរបស់សាលាឆាទ័រ។»

## ៥. ក្រុមប្រឹក្សានិបាលនៃសាលាឆាទ័រមានអង្គប្រជុំជាទៀងរាល់ខែៗ តើអង្គប្រជុំនេះអនុញ្ញាតឲ្យសាធារណៈជនចូលរួមដែរឬទេ?

អនុញ្ញាត។ គោលបំណងនៃសាលាឆាទ័រជាច្រើនគឺចង់ឲ្យសាលាមានភាពជិតស្និទ្ធជាមួយមាតាបិតា និងសហគមន៍ដែលសាលាផ្តល់ការបម្រើ និងស្វាគមន៍ការចូលរួមរបស់សហគមន៍។ ដោយសារសាលាឆាទ័រជាស្ថាប័នសាធារណៈដែលឧបត្ថម្ភដោយប្រាក់ពន្ធអាករ សាលានេះត្រូវអនុលោមតាមច្បាប់ដែលមានឈ្មោះថា «Sunshine Law»។ ច្បាប់នេះ (ពាក់ព័ន្ធនឹងស្ថាប័នសាធារណៈទាំងអស់) ចែងថា ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិឲ្យគេផ្តល់ដំណឹង និង ចូលរួមក្នុងអង្គប្រជុំ នៅពេលគណកម្មការមានការប្រជុំអ្វីមួយ។ ច្បាប់ Sunshine ក៏ផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋទាំងអស់ផ្តល់មតិយោបល់នៅក្នុងអង្គប្រជុំបើកចំហរបស់ក្រុមប្រឹក្សាភិបាលនៃសាលាឆាទ័រ។

បើសិនជាលោកអ្នកចង់ចូលរួមប្រជុំ ឬមានយោបល់នៅក្នុងអង្គប្រជុំ លោកអ្នកអាចទាក់ទងសាលាឆាទ័រ ដើម្បីសួរនាំពីកាលបរិច្ឆេទនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ សាលាឆាទ័រនីមួយៗគប្បីមានបិទប្រកាសអំពីអង្គប្រជុំប្រចាំឆ្នាំនៅសាលា។ លោកអ្នកក៏អាចសុំបញ្ជីឈ្មោះសមាជិកនៃក្រុមប្រឹក្សាភិបាលសាលាឆាទ័រ ដោយទាក់ទងទៅសាលាឆាទ័រ។

## ៦. សាលាឆាទ័របានសុំឲ្យខ្ញុំចូលរួមក្នុងអង្គប្រជុំប្រចាំខែសម្រាប់មាតាបិតានៅថ្ងៃសិក្សា។ តើត្រូវធ្វើដូចម្តេច បើសិនជាខ្ញុំមិនអាចចូលរួមបាន?

សាលាឆាទ័រជាច្រើន ផ្តល់ឱកាសឲ្យ មាតាបិតា និងសហគមន៍ ចូលរួមក្នុងប្រតិបត្តិការរបស់សាលា។ ទោះជាដូច្នេះក៏ដោយ ឆាទ័រមិនអាចបង្ខំមាតាបិតា ដោយតម្រូវឲ្យធ្វើអ្វីមួយដែលចាត់ទុកថាជាការបង់ ថ្លៃសាលា ឬ ថ្លៃអប់រំ បានទេ (ឧ. ការតម្រូវឲ្យមាតាបិតា «ស្ម័គ្រចិត្ត» មួយរយៈពេលនៅសាលា ជាល័ក្ខខ័ណ្ឌនៃការទទួលកូនរបស់គាត់ឲ្យចូលរៀន ឬ ឲ្យនៅរៀនតទៅទៀត)។ បើសិនជាលោកអ្នកមានសំណួរអំពីច្បាប់របស់សាលាឆាទ័រដែលកូនលោកអ្នករៀន លោកអ្នកត្រូវនិយាយជាមួយ អគ្គនាយក និង/ឬ ក្រុមប្រឹក្សាភិបាល សាលាឆាទ័រ។

## ៧. ហេតុអ្វីបានជាខ្ញុំឃើញគ្រូរបស់ក្រសួងអប់រំនៅសាលាឆាទ័រ?

គ្រូរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាប្រហែលជាសុំឈប់មួយរយៈពីក្រសួងអប់រំ ដើម្បីបង្រៀននៅសាលាឆាទ័រ។ ទោះជាយ៉ាងនេះក្តី គ្រូទាំងនោះត្រូវមានលក្ខណៈសម្បត្តិ ត្រូវតាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសរបស់សាលាឆាទ័រ មុនពេលពួកគាត់អាចបង្រៀននៅសាលាឆាទ័របាន។

## ៨. តើខ្ញុំអាចចុះឈ្មោះកូនរបស់ខ្ញុំឲ្យចូលរៀននៅសាលាឆាទ័រដែលបង្រៀនតាមអ៊ិនធ័រណិតដោយវិធីណា?

មាតាបិតាត្រូវពិនិត្យមើលបញ្ជីសាលាឆាទ័រដែលបង្រៀនតាមអ៊ិនធ័រណិត បន្ទាប់មក ទាក់ទងសាលាឆាទ័រដែលបង្រៀនតាមអ៊ិនធ័រណិតនីមួយៗ ដើម្បីជ្រាបព័ត៌មានបន្ថែម។ បើនៅមានសំណួរអំពីវិធីចុះឈ្មោះចូលរៀន សូមទាក់ទង Marlene Kanuck លេខ ៧១៧-៧៨៣-៩២៩៤។

## ៩. តើត្រូវធ្វើម្តេចទៅ បើសិនជាសាលារបស់ខ្ញុំគ្មានកីឡាដែលខ្ញុំចង់លេង?

អ្នកនៅតែអាចលេងនៅសាលារបស់ក្រសួងអប់រំដែលនៅក្នុងតំបន់បាន។ ច្បាប់សាលាឆាទ័រ (Act 22 នៃឆ្នាំ១៩៩៧) អនុញ្ញាតឲ្យសិស្សសាលាឆាទ័រចូលរួមក្នុងសកម្មភាពក្រៅម៉ោងសិក្សា។ អ្នកត្រូវតែលេងសាកល្បងជាមួយក្រុមកីឡាដែលអ្នកចង់លេង និងត្រូវតាមលក្ខខ័ណ្ឌនៃការ

ចូលរួម (ពេលវេលាហាត់ ម៉ោងធ្វើដំណើរទៅលេងកីឡា ។ល។)។ ច្បាប់របស់ក្រសួងអប់រំសម្រេចថាតើអ្នកអាចលេងក្នុងក្រុមនៃសាលាដែលនៅជិតសាលាឆាទ័ររបស់អ្នក ឬ ក្រុមនៃសាលាដែលនៅក្នុងតំបន់របស់អ្នក។ អ្នកប្រហែលជាត្រូវបង់ថ្លៃចូលរួមក្នុងកម្មវិធីក្រៅម៉ោងសិក្សានេះ។

**១០. តើនឹងមាន ពិធីជប់លៀងនៅពេលចប់ការសិក្សាពីវិទ្យាល័យ (prom) ដែរឬទេ នៅសាលាឆាទ័រ?**

ប្រហែលជាមាន។ សាលាឆាទ័ររៀបចំ កាលវិភាគ កម្មវិធីសិក្សា និងសកម្មភាពសម្រាប់សិស្ស ដោយខ្លួនឯង។ កម្មវិធីសម្រាប់ថ្នាក់វិទ្យាល័យភាគច្រើនផ្តល់ សកម្មភាពជាច្រើនសម្រាប់សិស្ស - សកម្មភាពតាមទម្លាប់ដែលធ្លាប់មាន និង សកម្មភាពថ្មីៗ ជាច្រើន។

**១១. តើសិស្សសាលាឆាទ័រអាចចុះឈ្មោះច្រៀងជាមួយ ក្រុមចម្រៀងជាពួក ឬ លេងភ្លេងជាមួយវង់តន្ត្រី ទូទាំងក្រុង បានដែរឬទេ?**

បាន។ បើសិនជាអ្នកសម្តែងសាកល្បងជាប់។ ជាថ្មីម្តងទៀត គេអនុញ្ញាតឲ្យសិស្សសាលាឆាទ័រចូលរួមក្នុងសកម្មភាពក្រៅម៉ោងសិក្សា។

**១២. តើខ្ញុំអាចទៅរៀននៅ វិទ្យាល័យទទួលសិស្សដែលមានលក្ខណ:សម្បត្តិពិសេស បានដែរឬទេ បើសិនជាខ្ញុំរៀននៅសាលាឆាទ័រ?**

បាន។ បើសិនជាអ្នកមានលក្ខណៈសម្បត្តិត្រូវតាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស។ គេជំរុញឲ្យសិស្សសាលាឆាទ័រទៅចូលរួមពិពរណ៍វិទ្យាល័យ នៅពេលដែលពួកគេរៀនថ្នាក់ទី៧ និង ថ្នាក់ទី៨។ អ្នកផ្តល់ឱវាទនៅសាលាឆាទ័រ ទទួលសៀវភៅ និង លិខិតដាក់ពាក្យសំចូលរៀន នៅវិទ្យាល័យ ជាច្រើនច្បាប់។ សិស្សសាលាឆាទ័រអាចដាក់ពាក្យសុំចូលរៀននៅសាលារដ្ឋដោយសេរី - ទៅសាលាឆាទ័រ ទៅវិទ្យាល័យរបស់ក្រសួងអប់រំ ឬ ទៅសាលាឆាទ័រដែល រៀនតាមអ៊ិនធ័រណិត (អនុញ្ញាតឲ្យដោយ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា)។

**១៣. តើការសិក្សានៅសាលាឆាទ័រ អាចប៉ះពាល់ដល់ឱកាសចូលរៀននៅមហាវិទ្យាល័យល្អ របស់កូនខ្ញុំ ដែរឬទេ?**

ការសិក្សានៅសាលាឆាទ័រ មិនអាចសន្យាថាគេនឹងទទួលឲ្យចូលរៀននៅមហាវិទ្យាល័យនោះទេ។ សាលាឆាទ័រនីមួយៗ និង សិស្សម្នាក់ៗ ត្រូវគេវាយតម្លៃដោយផ្អែកទៅលើកត្តាផ្សេងៗ៖ ១) លក្ខណៈហ្មត់ចត់នៃសំណុំឯកសារនៃការសិក្សា ២) ពិន្ទុនៃការប្រឡង SAT ៣) សកម្មភាពក្រៅម៉ោងសិក្សាជាច្រើន ៤) គុណភាពនៃការសរសេររបស់សិស្ស និង ៥) ទម្ងន់នៃលិខិតគាំទ្ររបស់បុគ្គលិក នេះគ្រាន់តែរៀបរាប់មួយចំនួនតែប៉ុណ្ណោះ។

**បើមានសំណួរបន្ថែមទៀត?** សូមទាក់ទងមកយើងខ្ញុំតាមអ៊ីមែល [www.philasd.org/language/khmer/help](http://www.philasd.org/language/khmer/help)